ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៥.២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការលុបចោលដីកា លេខ ១២១ សសរ

## ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់សាលាខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ៩៤ / ០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញបទបញ្ជា លេខ ៣០ / បប ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បានឃើញសារាចរ លេខ ០៦ / សរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការកែទំរង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- បានឃើញភាពមិនប្រក្រតីស្តីពីការប្រគល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់ សាលាខេត្តសៀមរាបទៅអោយក្រុមហ៊ុនរ៉ូយ៉ាល់ហ្គ្រុប ( Royal Group ) លើប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ លេខ ០០៣០៩៩ / សរ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ប្រធាននាយកដ្ឋានសុរិយោដី
- យោងតាមការពិនិត្យភាពមិនប្រក្រតីនៃដីកាលេខ ១២១ / សសរ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការផ្ទេរប្រគល់ អាគារ និង ទីតាំងនៃសាលសន្និសីទទៅអោយក្រុមហ៊ុនរ៉ូយ៉ាល់ហ្គ្រុបរបស់សាលាខេត្តសៀមរាប

## សំរេច

**មាត្រា ១ :** លុបចោលដីកាលេខ ១២១ សសរ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់សាលាខេត្តសៀមរាប ស្តីពីការផ្ទេរប្រគល់អាគារ និងទីតាំងនៃសាលសន្និសីទ ដែលមានផ្ទៃដីទំហំ ៥០.៩៦៨ ម$^2$ និង អាគារធ្វើពីថ្មប្រក់ក្បឿង ចំនួន បីខ្នង ដែលសង់លើទីតាំងនោះ ដល់ក្រុមហ៊ុនរ៉ូយ៉ាល់ហ្គ្រុប ( Royal Group ) ដែលចុះហត្ថលេខាដោយអភិបាលរងទី ១ ខេត្តសៀមរាប ដោយមូលហេតុការផ្ទេរនេះមានភាពមិនប្រក្រតី ។

**មាត្រា ២ :** ចាត់ទុកជាមោឃៈនូវលិខិត លេខ ០០២ សជណ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៩ របស់សាលាខេត្តសៀមរាប ដែលចុះហត្ថលេខាដោយអភិបាលរងទី ១ ខេត្តសៀមរាប ជូនចំពោះលោកប្រធានក្រុមហ៊ុនរ៉ូយ៉ាល់ហ្រ្គុប ( Royal Group ) ។

**មាត្រា ៣ :** ចាត់ទុកជាមោឃៈនូវការប្រគល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ នៅខេត្តសៀមរាប លើប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ លេខ ០០៣០៩៩ សរ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៨ ដែលមិនសមស្របតាមនីតិវិធី ។

**មាត្រា ៤ :** ដោយមានភាពមិនប្រក្រតី លើប័ណ្ណសំគាល់សិទ្ធិ លេខ ០០៣០៩៩ សរ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៨ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ( អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ) ត្រូវចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុជូនសាលាខេត្តសៀមរាបជំនួសវិញ ។

**មាត្រា ៥ :** ប្រគល់ទីតាំងសាលសន្និសីទ ដែលបានដកហូតមកពីក្រុមហ៊ុនរ៉ូយ៉ាល់ហ្រ្គុប ទៅអោយអាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តសៀមរាបធ្វើការគ្រប់គ្រង និងប្រើប្រាស់សំរាប់គោលដៅរបស់រដ្ឋ ។

**មាត្រា ៦ :** រាជរដ្ឋាភិបាលមិនទទួលខុសត្រូវលើការខូចខាតកន្លងមកដែលមិនស្របនឹងនីតិវិធីស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

**មាត្រា ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប ក្រុមហ៊ុនរ៉ូយ៉ាល់ហ្រ្គុប ( Royal Group ) និង គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*សៀមរាប, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៩*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន:</u>

- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៧*
- *ឯកសារ- កាលប្បវត្តិ*